Embassy of Japan

**ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៣**

សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ជាទីគោរពរាប់អានដ៏ខ្ពង់ខ្ពស់។

ខ្ញុំ គូម៉ាម៉ារូ យូជិ ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំបានចាប់ផ្តើមបេសកកម្មនៅប្រទេសកម្ពុជា ជាទឹកដីដែលមានភាពសំបូរបែបនៃសម្បត្តិធម្មជាតិជាមួយនិងប្រវត្តិសាស្ត្រដ៏យូរលង់និងអស្ចារ្យនៅថ្ងៃទី៨ ខែមិនា ឆ្នាំ២០១៣ ហើយមកទល់ពេលនេះមានរយៈពេលជាង៤ខែហើយ។ ថ្ងៃនេះ ខ្ញុំសូមក្រាបបង្គំទូលថ្វាយនិងគោរពផ្ញើជូននូវសារលិខិតមួយនេះ ដើម្បីបង្ហាញអំពីចំណាប់អារម្មណ៍របស់ខ្ញុំចំពោះប្រទេសកម្ពុជាក្នុងរយៈពេល៤ខែកន្លងមកនេះ។ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែល សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ចំណាយពេលវេលាដ៏មានតំលៃក្នុងការអាននូវសារលិខិតមួយនេះ។

អ្វីដែលខ្ញុំមានការចាប់អារម្មណ៍ខ្ពស់បំផុត នៅពេលដែលទើបនឹងបានមកដល់ប្រទេសកម្ពុជាជាលើកដំបូងនោះគឺការបង្ហាញរបស់ប្រជាជនកម្ពុជានូវជំនឿទុកចិត្តនិងទឹកចិត្តស្រលាញ់មកកាន់ប្រទេសជប៉ុន។ ជាងនេះទៅទៀត ខ្ញុំបានទទួលនូវការថ្លែងអំណរគុណជាច្រើន ពីសំណាក់ប្រជាជនកម្ពុជាតាមស្ថាប័នគ្រប់ជាន់ថ្នាក់ ចំពោះជំនួយរបស់ប្រទេសជប៉ុនសំរាប់ការស្តារឡើងវិញនិងការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀត ខ្ញុំក៏បានឈ្វេងយល់អំពីការរំពឹងទុករបស់ប្រជាជនកម្ពុជា ចំពោះការរីកចំរើនទំនាក់ទំនងផ្នែកសេដ្ឋកិច្ចរវាងប្រទេសទាំងពីរក្នុងរយៈពេលថ្មីៗនេះ ជាពិសេសគឺការកើនឡើងនៃវិនិយោគិនពីប្រទេសជប៉ុន។ ក្នុងនាមខ្ញុំជាឯកអគ្គរាជទូតដែលមានកាតព្វកិច្ចក្នុងការឆ្លើយតបទៅនឹងជំនឿទុកចិត្តនិងការរំពឹងទុករបស់ប្រជាជនកម្ពុជា ខ្ញុំសូមប្តេជ្ញាខិតខំប្រឹងប្រែងឲអស់ពីកំលាំងកាយចិត្តរបស់ខ្ញុំដើម្បីពង្រឹងនិងពង្រីកទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរឲកាន់តែមានភាពស្និទ្ធស្នាលថែមទៀត។

ជាពិសេសឆ្នាំនេះគឺជាឆ្នាំនៃខួបអនុស្សាវរីយ៍លើកទី៦០នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសជប៉ុននិងប្រទេសកម្ពុជា។ រដ្ឋាភិបាលជប៉ុន និង រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកឆ្នាំ២០១៣ជាខួបអនុស្សាវរីយ៍លើកទី៦០នៃចំណងមិត្តភាពរវាងជប៉ុននិងកម្ពុជា ដោយបាននិងកំពុងតែប្រារព្ធនូវកម្មវិធីវប្បធម៌និងកម្មវិធីបំលាស់ប្តូរយុវជនផ្សេងៗជាច្រើនសណ្ឋានដោយមានការចូលរួមយ៉ាងសកម្មពីស្ថាប័នឯកជននានាផងដែរ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាតាមរយៈកម្មវិធីជាច្រើននេះគឺជាការចូលរួមចំនែកក្នុងការពង្រីកនូវទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរ ក៏ដូចជាការរឹតបណ្តឹងចំណងមិត្តភាពឲរឹងមាំមួយកំរឹតថែមទៀតរវាងប្រជាជាតិទាំងពីរ។ ជាងនេះទៅទៀត ខ្ញុំក៏បានភ្ជាប់ជូននូវមាតិកានៃកម្មវិធីវប្បធម៌ចំបងៗ ដែលនឹងរៀបចំឡើងដោយស្ថានទូតជប៉ុនរហូតដល់ខែធ្នូបំណាច់ឆ្នាំនៅក្នុងសារលិខិតនេះផងដែរ។ ខ្ញុំពិតជាមានសេចក្តីរីករាយយ៉ាងក្រៃលែងប្រសិនបើ សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី

*No.194, Moha Vithei Preah Norodom, Phnom Penh, Cambodia (P.O.BOX21, Phnom Penh)*
*Tel: 855 (23) 217 161~4, Fax: 855 (23) 216 162*

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីអញ្ជើញចូលរួមជាកិត្តិយសនៅក្នុងឱកាសដ៏រីករាយនិងមានអត្ថន័យទាំងនេះ។

លើសពីនេះទៅទៀត ឆ្នាំ២០១៣ក៏ជាឆ្នាំដ៏វិសេសវិសាលដែលសម័យប្រជុំពេញអង្គរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកត្រូវបានប្រារព្ធធ្វើឡើងនៅក្នុងប្រទេសកម្ពុជាហើយវាក៏ជាព្រឹត្តិការណ៍ប្រវត្តិសាស្រ្តដ៏គួរឲអបអរសាទរផងដែរសំរាប់ប្រទេសជប៉ុន។ នោះដោយសារតែ ភ្នំហ្វូជិ (Fuji-san) ដែលជាភ្នំតំណាងឲជំនឿនិងសិល្បៈរបស់ប្រជាជនជប៉ុនត្រូវបានជ្រើសរើសជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅក្នុងសម័យប្រជុំពេញអង្គមួយនេះ។ នៅក្នុងប្រទេសជប៉ុន រាល់សកម្មភាពទាំងឡាយនៅក្នុងសម័យប្រជុំនេះត្រូវបានផ្សាយបន្តផ្ទាល់ទូទាំងប្រទេសជារៀងរាល់ថ្ងៃ ហើយព័ត៌មានស្តីអំពីសេចក្តីសំរេចក្នុងការចុះបញ្ជីត្រូវបានទទួលសាទរយ៉ាងរីករាយនៅទូទាំងប្រទេសជប៉ុន។ ខ្ញុំផ្ទាល់ដែលជាឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា មានសេចក្តីត្រេកអរយ៉ាងពន់ពេកដែលសម័យប្រជុំដ៏សំខាន់សំរាប់ប្រទេសជប៉ុននេះត្រូវបានរៀបចំធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ដែលបង្ហាញឲឃើញពីការភ្ជាប់និស្ស័យដ៏ស្អិតរមួតរវាងប្រទេសទាំងពីរ។ ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំសូមបង្ហាញនូវគារវកិច្ចដឹងគុណចំពោះ សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដើរតួនាទីយ៉ាងសំខាន់ជាប្រធានក្នុងការរៀបចំសម័យប្រជុំពេញអង្គនេះឡើង។

ខ្ញុំបានកត់សម្គាល់ឃើញថា បច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជាកំពុងតែមានការប្រកួតប្រជែងការពិភាក្សាផ្នែកនយោបាយយ៉ាងសកម្មសម្រាប់ការបោះឆ្នោតថ្នាក់ជាតិនាថ្ងៃទី២៨ខាងមុខនេះ។ ក្នុងនាមជាប្រទេសភាគីមិត្តដ៏យូរអង្វែងរបស់ប្រទេសកម្ពុជា ខ្ញុំសូមបួងសួងអស់ពីដួងចិត្តសូមឲលទ្ធិប្រជាធិបតេយ្យនៃប្រទេសកម្ពុជាដំណើរការកាន់តែមានភាពប្រសើរឡើងតាមរយៈការបោះឆ្នោតថ្នាក់ជាតិលើកនេះ ហើយខ្ញុំសង្ឃឹមយ៉ាងជឿជាក់ថាដំណើរការនៃការបោះឆ្នោតនឹងប្រព្រឹត្តទៅប្រកបដោយ សន្តិភាព សេរីភាព និងសមភាព។

នៅថ្ងៃអនាគតខាងមុខនេះ ខ្ញុំនឹងបន្តបង្ហាញពីចំណាប់អារម្មណ៍របស់ខ្ញុំតាមរយៈសារលិខិតដូចដែលបានបកស្រាយខាងលើដើម្បីថ្វាយនិងផ្ញើជូន សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី។ ខ្ញុំសូមស្វាគមន៍រាល់មតិយោបល់ឬគំនិតស្ថាបនាទាំងឡាយពី សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី។

ជាចុងក្រោយនេះ ទូលបង្គំជាខ្ញុំសូមអនុញ្ញាតថ្វាយនិងជូននូវសព្ទសាធុការពរមហាប្រសើរសូម សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីប្រកបដោយសុខភាពល្អបរិបូរណ៍ជានិច្ច។

**គូម៉ាម៉ារុ យូជិ**
**ឯកអគ្គរាជទូត វិសាមញ្ញ និង ពេញសមត្ថភាព**
**ជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

## កម្មវិធីវប្បធម៌អបអរសាទរខួបអនុស្សាវរីយ៍លើកទី៦០
## នៃចំណងមិត្តភាពរវាងប្រទេសជប៉ុននិងកម្ពុជា
## រហូតដល់ខែធ្នូ

| | |
|---|---|
| ថ្ងៃទី ១៦ ដល់ ២២ ខែកញ្ញា | ការប្រគុំតន្ត្រីក្លាស៊ីកខួបអនុស្សាវរីយ៍លើកទី៦០ |
| ពាក់កណ្តាល ខែតុលា | ការប្រគុំតន្ត្រីរបស់កងកម្លាំងស្វ័យការពារជើងទឹកជប៉ុន<br>(នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន) |
| ថ្ងៃទី ២២ ដល់ ២៣ ខែតុលា | ការប្រគុំតន្ត្រីសំលេងនិងស្គរអាស៊ាន<br>(នៅសាលមហោស្រពចតុមុខ) |
| ថ្ងៃទី ៦ ដល់ ៧ ខែវិច្ឆិកា | ការប្រគុំតន្ត្រីក្លាស៊ីកតូយ៉ូតា<br>(នៅសាលមហោស្រពចតុមុខ) |
| ថ្ងៃទី ២៣ ដល់ ២៤ ខែវិច្ឆិកា | ការសំដែងរបាំនិងតន្ត្រីប្រពៃណីជប៉ុន<br>(នៅសាលមហោស្រពចតុមុខ) |
| ថ្ងៃទី ៥ ខែធ្នូ | ការសំដែងរបស់ក្រុមសិល្បៈករ AUNJ នៅមុខប្រាង្គប្រាសាទអង្គរវត្ត<br>(នៅលើឆាកខាងមុខ ប្រាង្គប្រាសាទអង្គរវត្ត) |

- ខាងក្រោមនេះជាអាស័យដ្ឋានគេហទំព័រដែលបង្ហាញអំពីព័ត៌មានផ្សេងៗអំពីប្រទេសជប៉ុន។

http://web-japan.org/